ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបន្ទាយមានជ័យ

សំណុំរឿងព្រហ្មទណ្ឌលេខ : ២៤៤

ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៦

សាលក្រមព្រហ្មទណ្ឌលេខ : ០៩(ដ)

ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តបន្ទាយមានជ័យ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តបន្ទាយមានជ័យ

សាលសវនាការលេខ : ០១ នៃសាលាដំបូងខេត្តបន្ទាយមានជ័យ

កាលបរិច្ឆេទបើកសវនាការ : ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៧ វេលា ព្រឹក

កាលបរិច្ឆេទប្រកាសសាលក្រម : ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ វេលា រសៀល

### ចៅក្រមជំនុំជម្រះ

លោក [redacted] ឋានៈ ប្រធានក្រុមប្រឹក្សា

លោក [redacted] ឋានៈ ចៅក្រមប្រឹក្សា

លោក [redacted] ឋានៈ ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ឋានៈ ព្រះរាជអាជ្ញារង

### ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted] ឋានៈ ក្រឡាបញ្ជី

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ: ២៤៤ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៦ ដែលមាន :

### ជនជាប់ចោទ

-ឈ្មោះ [redacted] ហៅ ប៊ាន ភេទប្រុស អាយុ៤៦ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតកើតនៅ ភូមិប៉ោយតាប៉ែន ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង អាសយដ្ឋានមុនពេលឃុំខ្លួននៅ ភូមិត្រពាំងសំរោង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ មុខរបរកម្មករ ។ ឪពុកឈ្មោះ [redacted] ស្លាប់ ម្តាយឈ្មោះ [redacted] ស់ ប្រពន្ធឈ្មោ [redacted] ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ : គ្មាន ។

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

កាលបរិច្ឆេទនៃការឃាត់ខ្លួន ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ ។

កាលបរិច្ឆេទនៃការឃុំខ្លួន ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៦ ។

ត្រូវជាប់ចោទពីបទ : **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិបន្ទាយមានរិទ្ធ ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ និងថ្ងៃទី២២ .២៤ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា៤០ **កថាខណ្ឌ៥** ចំណុច១ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការ



Scanned by CamScanner

ត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២។

-បានឃើញ : ដីកាសន្និដ្ឋានស្ថាពរលេខ ៩៧៨ អក ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៦

-បានឃើញ : ដីកាដំណោះស្រាយ ៤៨៤១ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦

-បានឃើញ : ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៦១០ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦

**អង្គហេតុកើតឡើងមានដូចតទៅ**

កាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង១៣ និង៣០នាទី កម្លាំងការិយាល័យបទល្មើសគ្រឿងញៀន សហការជាមួយមូលដ្ឋានកងរាជអាវុធហត្ថ ស្រុកថ្មពួក ដោយប្រើវិធានញុះញង់ឱ្យលក់ដោយខុសច្បាប់នូវសារធាតុញៀន បានប្រតិបត្តិការបង្ក្រាបករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយធ្វើការឃាត់ខ្លួនជនសង្ស័យម្នាក់ឈ្មោះ [redacted] ភេទប្រុស អាយុ៤៦ឆ្នាំ ព្រមទាំងចាប់យកវត្ថុតាងមួយចំនួនមាន គ្រឿងញៀនមេតំហ្វេតាមីនគ្រាប់ចំនួន៣៩៥(បីរយហាសិបប្រាំ) គ្រាប់ ម៉ូតូចំនួន០១គ្រឿងម៉ាក RYUKA CRUISER BIKE ពណ៌ខ្មៅ គ្មានស្លាកលេខ លេខតួលេខម៉ាស៊ីន ០០០៨៤៦ ទូរស័ព្ទចំនួនមួយគ្រឿងម៉ាក ខេមហ្វូន ពណ៌ទឹកប្រាក់លាយលឿង និងកូនថង់សម្រាប់ច្រកគ្រឿងញៀនមួយចំនួន។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យកំណត់ហេតុ ឯកសារ ភស្តុតាងនានា និង ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងខេត្តបន្ទាយមានជ័យ**

**យល់ឃើញថា :**

-កាលពីអំឡុងឆ្នាំ២០១៦ និងថ្ងៃទី២២ .២៤ ខែមីនា ឆ្នាំ២០១៦ ពិតជាមានអង្គហេតុខាងលើបានកើតឡើង នៅចំណុចភូមិបន្ទាយមានរិទ្ធ ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ប្រាកដមែន។

-តាមការស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោ[redacted]នឆ្លើយថា: ខ្លួនពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន ដោយសមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ និងដកហូតបានថ្នាំញៀនចំនួន ៣៩៥(បីរយហាសិបប្រាំ) គ្រាប់។ ថ្នាំញៀននេះរបស់ឈ្មោ[redacted]អ្នកផ្ញើរនៅទីនឹងខ្លួនរយ:ពេលពីរថ្ងៃមុនពេលឃាត់ខ្លួន មានចំនួនពីរថង់ ក្នុងមួយថង់មានចំនួនពីររយគ្រាប់ សរុបបួនរយគ្រាប់ ដោយខ្លួនលក់អស់សែសិបប្រាំគ្រាប់ហើយ។ ឈ្មោះ [redacted]ានយកថ្នាំញៀនមកឱ្យខ្លួនលក់ចំនួនប្រាំដង ដោយក្នុងម្តង១មានពីពីរថង់ ទៅប្រាំថង់។ ខ្លួនលក់ថ្នាំញៀនក្នុងមួយគ្រាប់តម្លៃ១០០(មួយរយ) បាត។ ឈ្មោ[redacted]ានធ្លាប់ឱ្យខ្លួនយកថ្នាំញៀនទៅឱ្យឈ្មោះ [redacted] ផងដែរ ដោយក្នុងម្តងចំនួនមួយថង់។ លុយដែលបានពីលក់ថ្នាំញៀន ជូនកាលគេឱ្យទៅឈ្មោ[redacted]ជួនកាលគេទុកនឹងខ្លួន។ ខ្លួនធ្លាប់ទិញថ្នាំញៀនតែពីឈ្មោ[redacted]ណ្ណោះ។ នៅថ្ងៃឃាត់ខ្លួន មានគេកម្មង់ទិញថ្នាំញៀនចំនួន ១០(ដប់) គ្រាប់ ពេលយកថ្នាំញៀនទៅឱ្យពេក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

-តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៦៧៨២/១៦ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ



Scanned by CamScanner

២០១៦ លើសំណាកជាប្រភេទថ្នាំគ្រាប់ (ពណ៌ក្រហមក្បឿង និងពណ៌បៃតង) ឈ្មោះមេតំហ្វេតាមីន (Methamphe tamine) បរិមាណសារធាតុមេតំហ្វេតាមីន ដែលមានកម្រិតភាពសុទ្ធ ១០.៨៧% នៃទម្ងន់សរុប ស្ថិតក្នុងតារាងទី២ មាត្រា៩ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ឃើញថាថ្នាំញៀន ប្រភេទថ្នាំគ្រាប់(ពណ៌ក្រហមក្បឿង និងពណ៌បៃតង) ដែលដកហូតបានមានចំនួន៣៥៤.៥ (បីរយហាសិបបួនគ្រាប់កន្លះ) ហើយក្នុងមួយគ្រាប់ទម្ងន់ ០.០៩៣៧ ដែលមានកម្រិតភាពសុទ្ធមានចំនួន ១០.៨៧% នៃទម្ងន់សរុប ។ ដូចនេះ បរិមាណសុទ្ធនៃថ្នាំញៀនសរុប គឺ(០.០៩៣៧ ×៣៥៤.៥ ×១០.៨៧ = ៣.៦១ក្រាម) ។

-តាមកំណត់ហេតុចាប់យកវត្ថុតាងលើជនជាប់ចោទឈ្មោះ[redacted]ហៅ [redacted]ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០១៦ ធ្វើនៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ ដែលបញ្ជាក់ថាបានដកហូតថ្នាំញៀន ។

-ជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted]បានឆ្លើយសារភាពថា ខ្លួនពិតជាបានទិញថ្នាំញៀនពីឈ្មោះ[redacted] បានចំនួនប្រាំដង ហើយក៏ធ្លាប់កាន់ថ្នាំញៀនឱ្យឈ្មោះ[redacted]នេះផងដែរ ដើម្បីទទួលបានកម្រៃពីការលក់ថ្នាំញៀនប្រាកដមែន ។ ដែលចម្លើយទាំងអស់នេះមានភាពស៊ីសង្វាក់គ្នាទៅនឹងចម្លើយដែលរូបគេបានឆ្លើយនៅគ្រប់ដំណាក់កាលនៃនីតិវិធី រួមនឹងកំណត់ហេតុចាប់យកវត្ថុតាង ដែលបញ្ជាក់ថាបានដកហូតថ្នាំញៀនប្រភេទគ្រាប់ចំនួន ៣៥៥(បីរយហាសិបប្រាំ) គ្រាប់ ពីឈ្មោះ[redacted]ផ្ទាល់ផងដែរ ។ ដូចនេះ តាមអង្គហេតុ និងភស្តុតាងទាំងអស់ខាងលើនេះតុលាការជឿថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន ។

-តាមរយៈលទ្ធផលកោសលវិច័យគ្រឿងញៀនបានបង្ហាញថា បរិមាណសុទ្ធនៃថ្នាំញៀនសរុបត្រឹមតែ ៣.៦១ក្រាម នៃថ្នាំញៀនសរុបដែលដកហូបបាន ដែលកម្រិតភាពសុទ្ធនេះមិនត្រូវបានចាត់ចូលក្នុងកម្រិតបរិមាណសុទ្ធនៃថ្នាំញៀន ដែលត្រូវបានផ្តន្ទាទោសក្នុងបទឧក្រិដ្ឋនោះទេ ។ ម្យ៉ាងទៀតឈ្មោះ[redacted]ដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសពីមុនមកនេះដែរ ហើយនៅពេលសវនាការជនជាប់ចោទក៏បានឆ្លើយសារភាពនៅចំពោះមុខតុលាការដែលចម្លើយសារភាពនេះអាចឱ្យតុលាការជឿជាក់បាន ។

-ផ្អែកលើចម្លើយរបស់ជនជាប់ចោទ និងភស្តុតាងទាំងអស់ដែលមាននៅក្នុងសំណុំរឿង មានភាពស៊ីសង្វាក់គ្នា ដែលអាចឱ្យយើងធ្វើការសន្និដ្ឋានបានថា ជនជាប់ចោទពិតបានប្រព្រឹត្តបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន ប៉ុន្តែមិនមែនជាការជួញដូរដោយខុសច្បាប់នូវសារធាតុញៀនច្រើនដងនោះទេ ។ ហេតុនេះ គប្បីតុលាការសម្រេចកែប្រែបទចោទប្រកាន់លើជនជាប់ចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន(ច្រើនដង) មកបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។

-មិនមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted] ហៅ [redacted]ពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៥ ចំណុច១ និងមាត្រា៤៥នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២នោះទេ ប៉ុន្តែមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted]ពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ កថាខណ្ឌ៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ ២០១២ គប្បីតុលាការសម្រេចកែប្រែបទចោទប្រកាន់លើជនជាប់ចោទពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់**



Scanned by CamScanner

នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបន្ទាយមានរិទ្ធ ឃុំកោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ ២០១៦ និងថ្ងៃទី២២.២៤ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា៤០ **កថាខណ្ឌ៥** ចំណុច១ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ មកបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិបន្ទាយមានរិទ្ធ ឃុំកោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា ៤០ **កថាខណ្ឌ៣** កថាខណ្ឌ៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ វិញ ។

-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] ប្រព្រឹត្តឡើងក្នុងចេតនាទុច្ចរិត និងជាមនុស្សមានស្មារតីល្អនិងការយល់ដឹងបានច្បាស់លាស់ពីអំពើនិងបច្ច័យដែលកើតមានឡើងដោយ អំពើរបស់ខ្លួនតែជនជាប់ចោទរូបនេះនៅតែប្រព្រឹត្តបទល្មើស ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់សារធាតុញៀន ដែលអំពើនេះធ្វើឱ្យប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់ អសន្តិសុខសង្គម របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ និងខុសនឹងច្បាប់ព្រហ្មទណ្ឌជាធរមាន ។

-វត្ថុតាងដែលរឹបអូសបានមាន :

-ថ្នាំញៀនប្រភេទថ្នាំគ្រាប់ចំនួន ៣៤៥.៥គ្រាប់(បីរយសែសិបប្រាំគ្រាប់កន្លះ) ដែលមានពណ៌ត្នោយចំនួន ០១ (មួយ)គ្រាប់ និងពណ៌ក្រហមចំនួន ៣៤៤.៥គ្រាប់(បីរយសែសិបបួនគ្រាប់កន្លះ) ដែលនៅសល់ពីការដកហូតពីសំណាក់កោសល្យវិច័យ គឺជាវត្ថុតាងពិតប្រាកដនៃបទល្មើស ដូចនេះ តុលាការគប្បីសម្រេចរឹបអូស ។

-ជនជាប់ចោទឈ្មោះ [redacted] ត្រូវបានព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ចោទប្រកាន់ពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២០៦ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ យោងតាមមាត្រា ១៣៧ (ការចោទប្រកាន់តែមួយ)នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការប្រកាសទោសតែមួយចំពោះជនជាប់ចោទ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា : សំណុំរឿងព្រហ្មទណ្ឌលេខ ២៤៤ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៦ មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកសម្រាប់ចោទប្រកាន់ឈ្មោះ[redacted]ហៅ ហ៊ាន ពីបទ: **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ទុកជាបានការពេញលេញទាំងមូលនិងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted] ហៅ [redacted]ានធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តីរបស់ខ្លួនមានលក្ខណៈសមហេតុផល តុលាការនឹងលើកមកពិចារណាតាមផ្លូវច្បាប់ ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ហៅ[redacted]បានសំណូមពរថា សូមឱ្យតុលាការមេត្តាសម្រេចបន្ធូរបន្ថយទោសឱ្យរូបខ្លួន ។

**ហេតុដូច្នេះ សាលាដំបូងខេត្តបន្ទាយមានជ័យ**

**វិនិច្ឆ័យសេចក្តី**

១-កែប្រែបទចោទលើជនជាប់ចោទឈ្មោះ[redacted] ហៅ [redacted] ភេទប្រុស អាយុ៤៦ឆ្នាំ ពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិបន្ទាយមានរិទ្ធ ឃុំកោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ



Scanned by CamScanner

កាលពីអំឡុងឆ្នាំ២០១៦ និងថ្ងៃទី២២ .២៤ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៥ **ចំណុច១** និងមាត្រា **៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ មកបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិបន្ទាយមានរិទ្ធ ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា **៤០** កថាខណ្ឌ៣ កថាខណ្ឌ៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ ។

២-ផ្តន្ទាទោស :

ឈ្មោះ[redacted]ភេទប្រុស អាយុ៤៦ឆ្នាំ **ដាក់ពន្ធនាគារកំណត់រយៈពេល** ០៤(បួន) **ឆ្នាំ និងពិន័យ** ជាប្រាក់ចំនួន ៤.០០០.០០០(បួនលាន)**រៀល ចូលថវិការដ្ឋ** ពីបទ : **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវ** សារធាតុញៀន ប្រព្រឹត្តនៅភូមិបន្ទាយមានរិទ្ធ ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា ៤០ **កថាខណ្ឌ៣ កថាខណ្ឌ៤** និងមាត្រា **៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ ។

៣-រឹបអូសវត្ថុតាងមាន :

-ថ្នាំញៀនប្រភេទថ្នាំគ្រាប់ចំនួន ៣៨៥.៥គ្រាប់(បីរយសែសិបប្រាំគ្រាប់កន្លះ) ដែលមានពណ៌ត្រួយចំនួន ០១ (មួយ) គ្រាប់ និងពណ៌ក្រហមចំនួន ៣៨៤.៥គ្រាប់(បីរយសែសិបបួន២ គាប់កន្លះ) ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]។

បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| | |
|---|---|
| ក្រឡាបញ្ជីសវនាការ | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| ហត្ថលេខា និង ត្រ[redacted] | ហត្ថលេខា និង ត្រ[redacted] |

| | |
|---|---|
| បានឃើញ | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម |
| ប្រធានក្រុមប្រឹក្សាជំនុំជម្រះ | បន្ទាយមានជ័យ,ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ |
| | ក្រឡាបញ្ជី |
| [redacted] | [redacted] |



Scanned by CamScanner